UNITED
NATIONS

# ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច

អត្ថបទដើម : ភាសាអង់គ្លេស

គណៈកម្មាធិការសិទ្ធិមនុស្ស
សម័យប្រជុំលើកទី ៦០
ចំណុចរបៀបវារៈ ទី ១៩

## សេវាប្រតិបត្តិការបច្ចេកទេស និងសេវាប្រឹក្សាយោបល់នៅក្នុងប្រទេសកម្ពុជា

សេចក្តីសំរេចចិតរបស់គណៈកម្មការសិទ្ធិមនុស្ស : ២០០៤/៧៩

*គណៈកម្មាធិការសិទ្ធិមនុស្ស*

*ដោយគិតពី* សេចក្តីសំរេចចិត្តរបស់ខ្លួនលេខ ២០០៣/៧៩ ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៣ ហើយនិងសេចក្តីសំរេចចិត្តរបស់មហាសន្និបាត អ.ស.ប លេខ ៥៨/១៩១ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៣ ព្រមទាំងសេចក្តីសំរេចចិត្តមុនៗដែលទាក់ទង។

*សូមស្វាគមន៍* ចំពោះរបាយការណ៍របស់មហាសន្និបាត អ.ស.ប (E/CN.4/2004/104) ក៏ដូចជារបាយការណ៍របស់លោកតំណាងពិសេសនៃលោកអគ្គលេខាធិការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (E/CN.4/2004/105)

*ដោយទទួលស្គាល់* ប្រវត្តិដ៏សោកនាដកម្មនាពេលថ្មីៗនេះរបស់កម្ពុជា ដែលតម្រូវអោយមានការចាត់វិធានការជាពិសេសដើម្បីធានាការពារសិទ្ធិមនុស្ស និងដើម្បីកុំឱ្យវិលត្រឡប់ទៅរកនយោបាយ និងទម្លាប់អនុវត្តន៍ចាស់ពីអតីតកាល ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោ-

បាយដ៏ទូលំទូលាយមួយនៃជំលោះនៃប្រទេសកម្ពុជាដែលបានចុះហត្ថលេខា នាទីក្រុងប៉ារីស កាលពីថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១ ។

## I- តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម :

១- *សូមស្វាគមន៍* កិច្ចព្រមព្រៀងដែលបានធ្វើឡើងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតអង្គជំនុំជំរះវិសាមញ្ញ ដែលអនុវត្តយុត្តាធិការរបស់ខ្លួន ស្របតាមបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ភាពត្រឹមត្រូវ កិច្ចដំណើរការត្រូវតាមច្បាប់ ដូចដែលមានចែងក្នុងមាត្រា១២ នៃកិច្ចព្រមព្រៀង សូមស្នើទទូចដល់អគ្គលេខាធិការអ.ស.ប និងរដ្ឋាភិបាលកម្ពុជាអោយចាត់វិធានការចាំបាច់គ្រប់បែបយ៉ាង ដើម្បីបង្កើតអង្គជំនុំជំរះនេះអោយបានឆាប់រហ័ស ហើយសូមអំពាវនាវដល់សហគមអន្តរជាតិឱ្យជួយផ្តល់ជំនួយ រួមមានជំនួយខាងផ្នែកបុគ្គលិក និងហិរញ្ញវត្ថុ ដល់អង្គជំនុំជំរះវិសាមញ្ញនេះ តាមសេចក្តីសំរេចចិត្តរបស់លោកអគ្គលេខាធិការអ.ស.ប លេខ (57/228 B ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៣ )

## II- លទ្ធិប្រជាធិបតេយ្យ និងសភាពការណ៍សិទ្ធិមនុស្ស

២- *សូមស្វាគមន៍* ការបញ្ចប់ប្រកបដោយសន្តិភាពជាទូទៅ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលបានធ្វើឡើង កាលពីខែកក្កដា ឆ្នាំ២០០៣ ដែលបានបង្ហាញអោយឃើញអំពីភាពរីកចំរើនជាលំដាប់នៃដំណើរការលិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដោយទទឹមគ្នានេះទទួលស្គាល់ពីការចាំបាច់ត្រូវធ្វើការពង្រឹងបន្ថែមទៀតនូវសមត្ថភាពក្នុងការពង្រីកការប្រតិបត្តិ និងភាពមិនលំអៀងរបស់គណៈកម្មាធិ-ការជាតិរៀបចំការបោះឆ្នោត ។

៣- *សូមស្នើយ៉ាងទទូច* ដល់ភាគីពាក់ព័ន្ធឱ្យខិតខំប្រឹងប្រែងឱ្យបានអស់លទ្ធភាព ដើម្បីបង្កើតរដ្ឋាភិបាលថ្មីមួយអោយបានឆាប់រហ័ស និងដើម្បីដោះស្រាយរាល់បញ្ហាដែលពាក់ព័ន្ធ តាមមធ្យោ-បាយសន្តិវិធី និងប្រជាធិបតេយ្យ ។

៤- *សូមស្វាគមន៍* ការរីកចំរើន ដែលប្រទេសកម្ពុជាបានធ្វើឱ្យសភាពការណ៍សិទ្ធិមនុស្សបានកាន់តែប្រសើរឡើងនៅក្នុងទសវត្សកន្លងមកនេះ  ក៏ប៉ុន្តែនៅតែមានការព្រួយបារម្ភអំពីការរំលោភសិទ្ធិមនុស្ស ដែលនៅតែកើតមានជាបន្ត រួមដោយរួមទាំងការធ្វើទារុណ្ណកម្ម ការឃុំខ្លួនហួសរយៈពេលកំណត់មុនសវនាការ បញ្ហាទាក់ទងកំណែទម្រង់ដីធ្លី ក៏ដូចជាអំពើហឹង្សាប្រឆាំងនឹងសកម្មជននយោបាយ និងស៊ីវិល ហើយ

កត់សំគាល់ជាពិសេស ចំពោះបញ្ហាដែលនៅតែមានជាបន្តទាក់ទងនឹងនីតិរដ្ឋ និទណ្ឌភាព និងអំពើពុករលួយ ។

៥- *សូមស្នើយ៉ាងទទូច* ដល់រដ្ឋាភិបាលកម្ពុជា

(ក) ឱ្យពង្រឹងការខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការកសាងនីតិរដ្ឋ ដោយរួមទាំងតាមរយៈការអនុម័ត និងការអនុវត្តច្បាប់ និងក្រមសំខាន់ៗ សំរាប់បង្កើតសង្គមប្រជាធិបតេយ្យ និងឱ្យលើកឡើងដោះស្រាយ ដោយចាត់ទុកជាបញ្ហាអាទិភាព មានជាអាទិ៍ បរិយាកាសនិទណ្ឌភាព និងឱ្យបង្កើនការខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើការស៊ើបអង្កេតជាបន្ទាន់ និងកាត់ទោសទៅតាមនិតិវិធីត្រឹមត្រូវរបស់ច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ រួមទាំងបទរំលោភសិទ្ធិមនុស្សផង ។

(ខ) ឱ្យជំរុញកំណែទម្រង់ប្រព័ន្ធយុត្តិធមិរបស់ខ្លួន ឱ្យបានប្រសើរថែមទៀត ជាពិសេសដោយពង្រឹងការខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការធានាអំពីឯករាជ្យភាព ភាពមិនលំអៀង និងប្រសិទ្ធិភាពដល់ប្រព័ន្ធយុត្តិធមិទាំងមូល ។

(គ) ឱ្យចាត់វិធានការចាំបាច់គ្រប់បែបយ៉ាង ដើម្បីអនុវត្តឱ្យបានសំរេចនូវកាតព្វកិច្ចរបស់ខ្លួនក្រោមលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ និងអោយបន្តធ្វើសហប្រតិបត្តិការ ជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងជាមួយទីភ្នាក់ងារផ្សេងទៀត របស់អង្គការសហប្រជាជាតិ ។

(ឃ) ឱ្យបន្តការខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើឱ្យសិទ្ធិមនុស្សបានកាន់តែប្រសើរឡើងថែមទៀត ជាពិសេសសិទ្ធិស្ត្រី និងកុមារ និងឱ្យខិតខំថែមទៀតក្នុងការរួមសហការជាមួយសហគមអន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាជាគន្លឹះមួយចំនួន ដូចជាការជួញដូរមនុស្ស អំពើហឹង្សាផ្លូវភេទ អំពើហឹង្សាក្នុងគ្រួសារ និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។

(ង) ឱ្យបន្តបង្កើតនូវបរិយាកាស ដែលជួយឱ្យសកម្មភាពនយោបាយបានដំណើរការដោយស្របច្បាប់ ក៏ដូចជាឱ្យជួយគាំទ្រដល់តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីធ្វើឱ្យការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជាកាន់តែរឹងមាំ ។

## III- សេចក្តីសន្និដ្ឋាន

៦- *សូមអញ្ជើញ* លោកអគ្គលេខាធិការ និងសហគមន៍អន្តរជាតិ រួមទាំងអង្គការក្រៅរដ្ឋាភិបាលនានាឱ្យបន្តជួយឧបត្ថម្ភជាពិសេស លើវិស័យកសាងសមត្ថភាពដល់រដ្ឋាភិបាលកម្ពុជាក្នុងការធ្វើឱ្យលិទ្ធិប្រជាធិបតេយ្យកាន់តែល្អប្រសើរថែមទៀត ក៏ដូចជាក្នុងការការពារ និងលើកស្ទួយសិទ្ធិមនុស្សដល់ជនគ្រប់រូបនៅក្នុងប្រទេសកម្ពុជា ។

៦- *សូមស្នើផងដែរ* ដល់លោកអគ្គលេខាធិការអ.ស.ប សូមឱ្យរាយការណ៍ជូនគណៈកម្មាធិការនៅក្នុងសម័យប្រជុំលើកទីហុកសិបមួយ (៦១) របស់គណៈកម្មាធិការនេះ អំពីតួនាទី និងសមិទ្ធិផលនានាដែលការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សសំរេចបាន ក្នុងការជួយដល់រដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងអំពីអនុសាសន៍ ដែលធ្វើឡើងដោយលោកតំណាងពិសេសនៃអគ្គលេខាធិការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាលើបញ្ហានានាដែលស្ថិតនៅក្នុងអាណត្តិរបស់លោក ។

៨- *សំរេច* និងបន្តធ្វើការពិនិត្យពិចារណាស្តីពីសភាពការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជានៅក្នុងសម័យប្រជុំលើកទីហុកសិបមួយ ក្រោមចំណុចរបៀបវារៈដដែល ។

<u>បកប្រែពីអត្ថបទដើមជាភាសាអង់គ្លេស</u>